YUNNAN DAILY PRESS GROUP
云南日报报业集团
No.198

# ប្រទេសចិន-ខេត្តយូនណាន

រស្មីកម្ពុជា ប្រចាំថ្ងៃ

klunerlight@163.com
yunnangateway.com
Follow Amazing Yunnan on Facebook

ឆ្នាំទី27 លេខ8057 ថ្ងៃព្រហស្បតិ៍ ទី18 ខែតុលា ឆ្នាំ2019


## គម្រោងព្យាបាលជំងឺបេះដូង "ដំណើរចិត្តសប្បុរស" ចិន-កម្ពុជាទទួលការកោតសរសើរពីសំណាក់ប្រជាជនខ្មែរ

កុមារខ្មែរឈ្មោះសុខ លីន ដែលមកពីខេត្តតាកែវនិង ភឿង សារា ដែលមកពីខេត្តបាត់ដំបង មានផ្ទះនៅឆ្ងាយពីគ្នាជាង៣០០ គីឡូម៉ែត្រ ប៉ុន្តែគេពីរនាក់កំពុងរស់នៅដោយមានភាពសប្បាយរីករាយដូចគ្នា ។ ជាងមួយឆ្នាំមុនកុមារខ្មែរពីរនាក់នោះ នៅតែរងគ្រោះពីជំងឺបេះដូងតាំងពីកើត ។ ដោយសារបានទទួលជំនួយឧបត្ថម្ភពីគម្រោងព្យាបាលជំងឺបេះដូង"ដំណើរចិត្តសប្បុរស"ចិន-កម្ពុជាសុខ លីន និងភឿងសារាកំពុងរស់នៅយ៉ាងសប្បាយរីករាយដូចក្មេងៗដែលមានសុខភាពល្អ ។



កុមារខ្មែរម្នាក់ ដែលទទួលការវះកាត់បេះដូងនៅ ប្រទេសចិនទទួលកាដូពីមិត្តចិន

នៅខែមករាឆ្នាំ ២០១៨ ប្រទេសចិន និងកម្ពុជាបានចុះហត្ថលេខាលើអនុស្សរណៈយោគយល់ស្តីពីការជួយព្យាបាលជំងឺបេះដូងរបស់កុមារខ្មែរ។ មន្ទីរពេទ្យព្យាបាលជំងឺបេះដូងនិងសរសៃឈាមហ្វូវៃ ខេត្តយូនណានទទួលបន្ទុកអនុវត្តន៍គម្រោងនេះ។ តាំងពីឆ្នាំ២០១៨វៀងមក លោក ម៉ា លីនគុនអនុប្រធានមន្ទីរពេទ្យហ្វូវៃបានដឹកនាំក្រុមគ្រូពេទ្យ និងអ្នកស្ម័គ្រចិត្តទៅប្រទេសកម្ពុជា៤លើក ដើម្បីពិនិត្យសុខភាពបេះដូងរបស់កុមារខ្មែរ ។ ពួកគេបានធ្វើដំណើរទៅដល់សាលារៀនចំនួន៨១ នៅខេត្តបាត់ដំបង សៀមរាប កំពង់ធំ កំពង់ចាម និងត្បូងឃ្មុំដើម្បីរកកុមារខ្មែរដែលមានជំងឺបេះដូងតាំងពីកើត ។

ក្រោមការខិតខំប្រឹងប្រែងរបស់គ្រូពេទ្យចិននិងខ្មែរ សិស្សខ្មែរថ្នាក់បឋមសិក្សានិងមធ្យមសិក្សាជាង៣,៨ម៉ឺននាក់ បានទទួលនូវការពិនិត្យសុខភាពបេះដូង ។ លទ្ធផលនៃការពិនិត្យសុខភាព បានបង្ហាញឱ្យឃើញថាមានសិស្ស៣១៣នាក់មានលទ្ធភាពអាចមានជំងឺបេះដូងតាំងពីកើតហើយមាន៨២នាក់បានត្រូវសន្និដ្ឋានថាមានជំងឺបេះដូងតាំងពីកើត ។ គិតមកដល់ពេលនេះ មានសិស្សខ្មែរ៥២ នាក់បានទទួលការវះកាត់ដោយឥតគិតថ្លៃនៅក្រុងគុនមីងនៃប្រទេសចិន ។

ក្នុងគំនិតរបស់កុមារខ្មែរដែលធ្លាប់ទទួលការវះកាត់នៅប្រទេសចិនមន្ទីរពេទ្យហ្វូវៃជាកន្លែងមួយដែលពោរពេញទៅដោយការចងចាំដ៏ល្អប្រសើរ ។ នៅខែឧសភា ឆ្នាំនេះ សុខ-លីនបានទទួលការវះកាត់នៅប្រទេសចិន។ ជីដូនរបស់សុខ លីនបានប្រាប់អ្នកកាសែតថាមន្ទីរពេទ្យចិនបានជួយយើងច្រើនណាស់ ។ គ្រូពេទ្យនិងគិលានុបដ្ឋាយិកាចិនមានស្មារតីទំនួលខុសត្រូវកម្រិតខ្ពស់ដែលបានធ្វើឱ្យយើងមានចិត្តរំភើបជាប់រហូត ។ ក្រោយពីទទួលការវះកាត់នៅប្រទេសចិនភឿងសារា ក៏មានសុខភាពល្អឡើងវិញដែរ។ សព្វថ្ងៃ គាត់អាចជិះកង់បានហើយក៏មិនមានរាងស្គមដូចកាលមុនទេ ។ ភឿង-សារា បានបញ្ជាក់ថាខ្ញុំមានចិត្តដឹងគុណចំពោះគ្រូពេទ្យចិន។

លោក ជា មុនីឫទ្ធិ ប្រធាននាយកដ្ឋានផែនការនិងគម្រោងនៃវេទិកាសម្ព័ន្ធសង្គមស៊ីវិលទីស្តីការគណៈរដ្ឋមន្ត្រីកម្ពុជាបានលើកឡើងថាកុមារខ្មែរទាំងនោះនឹងដឹងគុណគ្រូពេទ្យចិនជានិច្ច ។ គ្រូពេទ្យចិនបានជួយព្យាបាលជំងឺរបស់គេឱ្យជាសះស្បើយ ។ ក្នុងក្រអៅបេះដូងរបស់ពួកគេនឹងអាចដុះគ្រាប់ពូជមិត្តភាពជានិច្ចកាល ។

មន្ទីរពេទ្យហ្វូវៃ បានបណ្តុះ-បណ្តាលគ្រូពេទ្យខ្មែរ១០ រូបនៅក្រុងគុនមីងដើម្បីឱ្យកុមារខ្មែរដែលមានជំងឺបេះដូងកាន់តែច្រើនអាចទទួលការព្យាបាលជំងឺនៅក្នុងប្រទេសកម្ពុជា។ មិនតែប៉ុណ្ណោះមន្ទីរពេទ្យហ្វូវៃបានជួយមន្ទីរពេទ្យមិត្តភាពចិន-កម្ពុជាព្រះកុសុមៈបង្កើតមជ្ឈមណ្ឌលព្យាបាលជំងឺបេះដូង ។ ក្នុងរយៈពេលមួយឆ្នាំកន្លងទៅនោះតាមរយៈគម្រោង "ដំណើរចិត្តសប្បុរស"នេះគ្រូពេទ្យចិននិងខ្មែរបានបណ្តុះបណ្តាលគ្រូពេទ្យនិងនិស្សិតខ្មែរ២៤នាក់ហើយបានបណ្តុះ-បណ្តាលគ្រូពេទ្យខ្មែរ៧០នាក់ដោយប្រើរថយន្តសុខាភិបាល ។ កិច្ចសហ-ប្រតិបត្តិការសុខាភិបាលរវាងប្រទេសចិននិងកម្ពុជាមិនគ្រាន់តែបានផ្តល់ផល-ប្រយោជន៍ដល់ប្រជាជននៃប្រទេសទាំងពីរប៉ុណ្ណោះទេ ថែមទាំងបានក្លាយទៅជា "គម្រោងតភ្ជាប់ក្រអៅបេះដូងប្រជាជន" ដែលបានរួមចំណែកក្នុងការពង្រឹងចំណងមិត្តភាពចិន-កម្ពុជាទៀតផង ។

**ដោយ ទីង ជឺនិង លីន យូយ**
**(កាសែតប្រជាជនដេលី)**

## ឯកឧត្តម ស៊ី ជីនភីង បកស្រាយពីការងារផ្តល់ជំនួយសុខាភិបាលដល់បរទេស

ការងារផ្តល់ជំនួយសុខាភិបាលដល់បរទេសជាភារកិច្ចមួយដែលមានការលំបាក និងមានកិត្តិយស ។ ក្នុងរយៈពេលកន្លះសតវត្សរ៍កន្លងទៅប្រទេសយើងបានបញ្ជូនគ្រូពេទ្យ២,៣ម៉ឺននាក់ទៅកាន់ប្រទេសនិងតំបន់ចំនួន ៦៦ ក្នុងទ្វីបអាស៊ីអាហ្វ្រិក អាម៉េរិកឡាទីននិងអូសេអានី ជាដើមហើយបានជួយព្យាបាលជំងឺឱ្យអ្នកជំងឺ២៧០លាននាក់ដែលបានទទួលការជឿទុកចិត្តយ៉ាងពេញលេញនិងការកោតសរសើរជាទូទៅពីសំណាក់ប្រជាជននៃបណ្តាប្រទេសនានាដែលទទួលជំនួយសុខាភិ-បាលពីប្រទេសចិន ។ យើងបានខិតខំអភិវឌ្ឍន៍បុព្វហេតុនេះ៥០ ឆ្នាំហើយពិតជាអស្ចារ្យណាស់ ។

**(ដកស្រង់ចេញពីសុន្ទរកថារបស់ឯកឧត្តមស៊ី ជីនភីងដែលថ្លែងក្នុងជំនួបជាមួយតំណាងសមូហភាពនិងបុគ្គលគំរូចិនដែលចូលរួមគម្រោងផ្តល់ជំនួយសុខាភិបាលដល់បរទេសនៅថ្ងៃទី ១៦ ខែសីហា ឆ្នាំ២០១៧)**

## ពិព័រណ៍នាំចូលចិនអន្តរជាតិលើកទី២នឹងបើកពិព័រណ៍នៅខែវិច្ឆិកាក្នុងក្រុងសៀងហៃ

ពេលថ្មីៗនេះមន្ទីររៀបចំ ពិព័រណ៍នាំចូលចិនអន្តរជាតិ និងមន្ទីរពាណិជ្ជ-កម្មខេត្តយូនណានបានរៀបចំកម្មវិធីទាក់ទាញអ្នកវិនិយោគនៃពិព័រណ៍នាំចូលចិនអន្តរជាតិលើកទី២ ។ តាមប្រភពព័ត៌មានពីស្ថាប័នពាក់ព័ន្ធ បានឱ្យដឹងថា កាលពីថ្ងៃទី ៥ ដល់ទី១០ខែវិច្ឆិកា ឆ្នាំ២០១៩ ពិព័រណ៍នាំចូលចិនអន្តរជាតិលើកទី២នឹងរៀបចំក្នុងមជ្ឈមណ្ឌលសន្និសីទនិងពិព័រណ៍ជាតិក្រុងសៀងហៃ ។

គួរបញ្ជាក់ថា ពិព័រណ៍នាំចូលចិនអន្តរជាតិនេះបែងចែកជា៣ ផ្នែកគឺពិព័រណ៍នៃប្រទេសផ្សេងៗពិព័រណ៍សហគ្រាសនិងវេទិកាសេដ្ឋកិច្ចអន្តរជាតិហុងឈីវ ។ បើនិយាយចំពោះពិព័រណ៍នៃប្រទេសផ្សេងៗគិតមកដល់ពេលនេះមានប្រទេសចំនួន៦៤ បានសម្រេចចិត្តនឹងចូលរួមក្នុងពិព័រណ៍នេះហើយមានប្រទេសចំនួន ១៥រួមមានប្រទេសបារាំងអ៊ីតាលីនិងអ៊ូសបេគីស្ថានជាដើមនឹងចូលរួមជាប្រទេសកិត្តិយសនៃពិព័រណ៍នេះ។ បើនិយាយចំពោះពិព័រណ៍សហគ្រាសឆ្លងតាមរយៈការរៀបចំជាងកន្លះឆ្នាំយើងបានសម្រេចនូវគោលដៅនៃការរៀបចំតំបន់ពិព័រណ៍ដែលមានទំហំជាង៣សែនម៉ែត្រការ៉េ ជាពិសេសប្រទេសសហគ្រាសប្រទេសតាមបណ្តោយ"ខ្សែក្រវាត់មួយនិងផ្លូវមួយ" និងសហគ្រាសឈានមុខទាំង៥០០លើពិភពលោកដែលចូលរួមការតាំងពិព័រណ៍សុទ្ធតែមានចំនួនច្រើនជាងពិព័រណ៍លើកមុន ។ បើនិយាយចំពោះវេទិកាសេដ្ឋកិច្ចអន្តរជាតិហុងឈីវយើងនឹងប្រកាន់ខ្ជាប់នូវគោលការណ៍នៃការរៀបចំវេទិកាអន្តរជាតិកម្រិតខ្ពស់ដើម្បីពិគ្រោះពិភាក្សាគ្នាអំពីប្រធានបទសំខាន់ៗ មួយចំនួនដូចជាបរិស្ថានពាណិជ្ជកម្ម ប្រព័ន្ធ AI កំណែទម្រង់អង្គការពាណិជ្ជកម្មពិភពលោកនិងពាណិជ្ជកម្មអេឡិចត្រូនិកជាដើម ។

**ដោយ លី ហុងខាយ**

## "ពណ៌ក្រហមចិន" ដែលស្រស់ស្អាតជាងគេ

ក្នុងអំឡុងពេល៧០ឆ្នាំ ក្រោយពីប្រទេសចិនថ្មីត្រូវបានបង្កើតឡើងវៀងមកជីវភាពរស់នៅរបស់ប្រជាជនចិនត្រូវបានលើកកម្ពស់ជាបន្តបន្ទាប់ចំណែកទីផ្សារទេសចរណ៍ចិន ក៏បានត្រូវកែលម្អពីមួយថ្ងៃទៅមួយថ្ងៃដែរ ។ ប្រជាជនចិនមានតម្រូវការកាន់តែច្រើនឡើងៗ ។ គិតជាមធ្យម នៅឆ្នាំ ២០១៨ ប្រជាជនចិនម្នាក់បានទៅធ្វើទេសចរបួនដងក្នុងរយៈពេលមួយឆ្នាំហើយមានប្រជាជនចិនជាង៥.៥០០លាននាក់ទៅធ្វើទេសចរណ៍ក្នុងស្រុកស្មើនឹង១១ដងនៃចំនួនប្រជាជនចិនដែលធ្វើទេសចរក្នុងស្រុកនៅឆ្នាំ ១៩៩៤ ដែលបានសម្រេចនូវកំណើនប្រចាំឆ្នាំជាមធ្យម១០,៣ភាគរយ ។

**ដោយយ៉ាង ជឺង**



ក្នុងឱកាសបុណ្យជាតិចិននេះ ទេសចរថតរូបទុកជាអនុស្សាវរីយ៍នៅ មុខសួនផ្កាដែលផ្គុំជារាង "មហាកំពែង ដ៏ស្រស់ស្អាត" ក្នុងសួនបឹងឈុយហ៊្វូ

## ទិន្នន័យទេសចរណ៍បង្ហាញពីកម្លាំងប្រើប្រាស់ដ៏ខ្លាំងក្លា

ប្រជាជនជិត១៤០០លាននាក់ក្រុមអ្នកចំណូលកម្រិតមធ្យម ដែលមានទ្រង់ទ្រាយធំជាងគេលើពិភពលោក ចន្លោះទីផ្សារដ៏ធំធេង និងកម្លាំងទិញទំនិញដ៏ខ្លាំងក្លាបានក្លាយទៅជាកត្តាសំខាន់ដែលអាចពឹងផ្អែកបានសម្រាប់ផ្តល់កិច្ចធានាដល់ការអភិវឌ្ឍនៃសេដ្ឋកិច្ចចិន ។ ក្នុងឱកាសឈប់សម្រាកប្រាំពីរថ្ងៃនៃបុណ្យជាតិចិនឆ្នាំនេះ សមត្ថភាពចាយប្រាក់លើវិស័យទេសចរណ៍ចិនបានបង្កើតឯតទគ្គកម្មថ្មីៗ ក្នុងរយៈពេលប្រាំពីរថ្ងៃនោះ ប្រទេសចិនបានទទួលទេសចរជាតិ៧៨២លាននាក់កើនឡើង៧,៨១ភាគរយហើយបានទទួលចំណូល៦៤៩.៧១០លានយាន់ពីវិស័យទេសចរណ៍ក្នុងស្រុក កើនឡើង៨,៤៧ភាគរយបើប្រៀបធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំ២០១៨។ ទិន្នន័យគួរជាទីចាប់អារម្មណ៍ នេះ បានបង្ហាញពីកម្លាំងចលករផ្ទៃក្នុង ដ៏ខ្លាំងក្លារបស់ប្រទេសចិន ។ សមត្ថភាព ចាយប្រាក់បានក្លាយទៅជាក្បាលម៉ាស៊ីនដ៏សំខាន់សម្រាប់ការអភិវឌ្ឍន៍នៃសេដ្ឋកិច្ចចិន ។



ផ្សារលក់ផ្កាទូវណានក្រុងគុនមីងទាក់ទាញទេសចរដ៏ច្រើនមករើសទិញផ្កា ស្រស់គ្រប់ពណ៌

ក្នុងឱកាសឈប់សម្រាកនៃបុណ្យជាតិចិននេះ ការចាយប្រាក់លើវិស័យទិញទំនិញ និងហូបចាយ បានបង្ហាញពីកម្លាំងទាក់ទាញខ្លាំងគួរឱ្យកត់សម្គាល់ ។ តាមទិន្នន័យពីក្រសួងពាណិជ្ជកម្មចិនបានឱ្យដឹងថា ក្នុងអំឡុងពេលពីថ្ងៃទី១ដល់ទី៧ ខែតុលា វិស័យពាណិជ្ជកម្មលក់រាយ និងភោជនីយដ្ឋានទូទាំងប្រទេសចិន បានសម្រេចទំហំពាណិជ្ជកម្ម១,៥២ទ្រីលានយាន់ កើនឡើង៨,៥ភាគរយ បើប្រៀបធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំ២០១៨ ។ ក្នុងនោះ ភោជនីយដ្ឋានល្បីឈ្មោះ និងភោជនីយដ្ឋានដែលមានប្រជាប្រិយភាពតាមបណ្តាញអ៊ីនធឺណិត បានទទួល ការពេញនិយមយ៉ាងខ្លាំង។ទំហំពាណិជ្ជកម្មនៃភោជនីយដ្ឋានល្បីឈ្មោះ មួយចំនួននៅក្រុងប៉េកាំង បានកើនឡើង ប្រហែលទ្វេដងបើប្រៀបធៀបនឹងពេលធម្មតា ។

កម្មវិធីវប្បធម៌កាន់តែមានភាពសម្បូរបែប និងចម្រុះពណ៌ ។ តាមការសិក្សាពីក្រសួងវប្បធម៌ និងទេសចរណ៍ចិន បានឱ្យដឹងថា ក្នុងឱកាសឈប់សម្រាកនៃបុណ្យជាតិចិននេះមានទេសចរ៦៦,៤ភាគរយ បានទៅទស្សនាតំបន់ទេសចរណ៍វប្បធម៌និងមនុស្សសាស្ត្រ ហើយមានទេសចរ៥៩,៤៥ភាគរយ បានទៅទស្សនាតំបន់វប្បធម៌ និងប្រវត្តិសាស្ត្រ ។ តាមការសិក្សាស្រាវជ្រាវបានឱ្យដឹងថា ទស្សនិក-ជន នៃភាពយន្តចិនបានបង្ហាញពីកម្រិតពេញចិត្ត និងឱ្យ៨៨,៦ពិន្ទុចំពោះភាពយន្តដែលចាក់បញ្ចាំងក្នុងឱកាសបុណ្យជាតិចិននេះ ដែលជាកម្រិតពេញចិត្ត និងពិន្ទុខ្ពស់ជាងគេក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវនេះវៀងមក ។

**(កាសែតប្រជាជនដេលី)**